# សេចក្តីប្រកាសព័ត៌មាន

## ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ខែធ្នូ ឆ្នាំ ២០១៩<br>ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមនាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន<br>តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី<br>នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃអាទិត្យ ៥កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

សាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩

ដូចជារៀងរាល់ឆ្នាំ ក្នុងនាមរាជរដ្ឋាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តែងរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី១ ខែធ្នូ នេះ ជាទៀងទាត់នៅទូទាំង២៥ រាជធានី ខេត្ត ក្នុងបំណងបង្ហាញការប្តេជ្ញាចិត្តដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រំលឹកនូវការផ្តល់ការគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងរំលឹកនូវសោកនាដកម្មនៃអ្នកស្លាប់ដោយសារជំងឺអេដស៍ ព្រមទាំងក្រើនរំលឹកដល់ប្រជាពលរដ្ឋទូទាំងប្រទេស ឱ្យចងចាំជានិច្ចពីគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ដើម្បីឈានទៅលុបបំបាត់ការឆ្លងរីករាលដាលមេរោគអេដស៍ រួមចំណែកក្នុងការអភិវឌ្ឍរបស់មនុស្សជាតិ។

ដោយឡែកនៅរាជធានីភ្នំពេញ នាព្រឹក ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ នៅសាលសន្និសីទចតុមុខ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានប្រារព្ធទិវាប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី១ ធ្នូ ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមនាយឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងស្ថាប័នជាតិ និង អន្តរជាតិ តំណាងអង្គទូតនានា តំណាងក្រុមអ្នករស់នៅជាមួយមេរោគអេដស៍ ជំងឺអេដស៍ ដៃគូអភិវឌ្ឍ និង តំណាងសង្គមស៊ីវិល សរុបប្រមាណ ៧០០ នាក់ ។

- អត្រាប្រេវ៉ាឡង់អ្នកផ្ទុកមេរោគអេដស៍ មានការថយចុះជាបន្តបន្ទាប់តាំងពី ១,៧% នៅឆ្នាំ ១៩៩៨ មកនៅ០,៨% នៅឆ្នាំ២០១០ និងមកនៅត្រឹមតែ ០,៦% នៅឆ្នាំ២០១៨។
- តាមការសិក្សាតាមបែបវិទ្យាសាស្ត្រ នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៩ អ្នកផ្ទុកមេរោគអេដស៍ មានចំនួនប្រមាណ ៧៣.០០០នាក់។
- អ្នកបានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍ មាន៥៩.៥២៦នាក់ (ក្នុងឆ្នាំ២០១៨) និងមានប្រមាណជាង ៦០.០០០នាក់ ក្នុងឆ្នាំ២០១៩នេះ ។

- អ្នកឆ្លងថ្មីមានការថយចុះប្រមាណជា៦២% ចាប់ពីឆ្នាំ២០១០ មកដល់ឆ្នាំ២០១៨ ដែលតាមការប៉ាន់ប្រមាណអ្នកឆ្លងថ្មីក្នុងឆ្នាំ២០១៨នេះ មានចំនួន៨៨០នាក់។
- អ្នកស្លាប់ដោយមេរោគអេដស៍ ក៏មានការថយចុះប្រមាណជា ៤៨% ផងដែរ ចាប់ពីឆ្នាំ២០១០មក ដែលការស្លាប់នៅឆ្នាំ២០១៨កន្លងមកនេះ មានប្រមាណជា ១៣០០ នាក់។
- ការរាយការណ៍ពីការមាក់ងាយ និងរើសអើងពីខាងក្រៅមានការធ្លាក់ចុះ ជាពិសេសការបដិសេធមិនផ្តល់ការងារ ពី៤៦%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩ និងការបំពានជាពាក្យសំដី ពី១៤%នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩។ ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍អៀនខ្មាស នៅតែជាបញ្ហាគួរឱ្យកត់សម្គាល់នៅឡើយ ដោយមានអត្រា៧១,៥% នៅឆ្នាំ២០១០ មកនៅ ៦២,៧%នៅឆ្នាំ២១៩ ។
- ភាពជោគជ័យលើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជា គឺធ្វើឡើងដោយមានការចូលរួមទាំងអស់គ្នាតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ "**ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍**" ដែលមកដល់ពេលនេះជាលទ្ធផល ប្រទេស កម្ពុជាទទួលបានជោគជ័យ គួរជាទីមោទនៈ រួមមាន៖
- នៅឆ្នាំ២០០៦ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជាបានទទួលគោរម្យងារពីអង្គការសហប្រជាជាតិ ជា "ឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា"
- នៅឆ្នាំ២០០៩ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ក៏បានទទួលនូវ "ពានរង្វាន់វេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ីប៉ា-ស៊ីហ្វិកស្តីពីមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា" ពីអង្គការសហប្រជាជាតិជាថ្មីទៀត។
- ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានទទួលពានរង្វាន់ពីអង្គការសហប្រជាជាតិក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សលើការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- នៅឆ្នាំ២០១៧ អង្គការ UNAIDS បានប្រកាសទទួលស្គាល់ប្រទេសកម្ពុជាក្នុងចំណោមប្រទេសចំនួន៧ នៅក្នុងពិភពលោក (រួមមាន ចក្រភពអង់គ្លេស អ៊ីស្លង់ ដាណឺម៉ាក ស៊ុយអ៊ែតស៊ឹង្ហបុរី និងបុតស្វាណា) ថាជាប្រទេសដែលអាចសម្រេចបាននូវគោលដៅ ៩០ ៩០ ៩០ នាឆ្នាំ២០២០ មុនកាលកំណត់៕